# ការសំភាសន៍របស់បងស្រី ស្រឿន ណោត

កៈ អ្នកដែរសំភាសន៍គេមាន ជាងស៊ីអ៊ាវ ខៈ អ្នកដែរអោយគេសំភាសន៍ ស្រឿន ណោត

## <u>ការសង្ខេបប្រវត្តិរបស់បងស្រី ស្រឿន ណោត</u>

បងស្រី ស្រឿន ណោត មានអាយុ42ឆ្នាំ នៅឆ្នាំ2018 បងស្រី ស្រឿន ណោត មានភេទស្រីបងស្រី ស្រឿន ណោត មានទីលំនៅបច្ចុប្បន្ននៅភូមិវាលខ្សាច់ ឃុំរអាង ស្រុកកំពង់សៀម ខេត្តកំពង់ចាម។

កៈ ចឹងជាដំបូងខ្ញុំសូមអរគុណច្រើនបងដែរបានអោយខ្ញុំសំភាសន៍ពីប្រវត្តិរបស់បង ហើយការសំភាសន៍ នេះត្រូវបានរៀបចំឡើងដោយសកលវិទ្យាល័យមួយដែរនៅអាមេរិចដែរមានឈ្មោះថាBYU ហើយដោយសារតែសកលវិទ្យាល័យមានគោលបំណងចង់រក្សាពីប្រវត្តិប្រជាជនខ្មែរដើម្បីទុកអោយកូនចៅ ជំនាន់ក្រោយៗពួកគាត់បានស្គាល់ពីប្រវត្តិរបស់ឪពុកម្ដាយ នឹងប្រវត្តិរបស់ដូចតា ចឹងនៅពេលដែរខ្ញុំបាន សំភាសន៍បងហើយខ្ញុំនឹងដាក់ការសំភាសន៍មួយនេះទៅក្នុងវេបសាយរបស់សាលាដែរមាន ឈ្មោះថា www.cambodianoralhistories.byu.edu ចឹងហាសបង ចឹងតើបងយល់ព្រមដើម្បីអោយខ្ញុំដាក់ការសំភាសន៍ មួយនេះទៅក្នុងវេបសាយរបស់សាលាដែរទេបង?

ខៈ យល់ព្រម

កៈ ចឹងសំរាប់ខ្ញុំជាអ្នកដែរសំភាសន៍ខ្ញុំមានឈ្មោះថា ជាង ស៊ីអ៊ាវ ហើយថ្ងៃខែដែរខ្ញុំសំភាសន៍បងគឺត្រូវបាន ធ្វើឡើងនៅថ្ងៃទី19 ខែ2 ឆ្នាំ2018 នៅនឹងភូមិអីគេដែរបង?

ខៈ ភូមិវាលខ្សាច់

កៈ ភូមិវាលខ្សាច់ ចុះឃុំវិញបង?

ខៈ ឃុំរអាង ស្រុកកំពង់សៀម

កៈ ឃុំរអាង ស្រុកកំពង់សៀម ខេត្តកំពង់ចាម ចុះសំរាប់បងមានឈ្មោះពេញឈ្មោះអីគេដែរបង?

ខៈ ខ្ញមពេញរបស់ខ្ញុំនឹងឈ្មោះស្រឿន ណោត

កៈ មានឈ្មោះហៅក្រៅទេបង?

ខៈ មានដែរតើ!

កៈ មានឈ្មោះអីគេដែរបង?

ខៈ មានឈ្មោះទូច នឹងឈ្មោះហៅក្រៅរបស់ខ្ញុំនឹង

កៈ ចុះកាលពីក្មេងធ្លាប់មាននរណាហៅឈ្មោះបងអីផ្សេងទេបង?

ខៈ អត់មានទេមានតែឈ្មោះមួយនឹង

កៈ ចុះបងសព្វថ្ងៃនឹងបងអាយុប៉ុន្មានដែរបង?

ខៈ ខ្ញុំអាយុ42ឆ្នាំហើយនឹង

កៈ ប្អូនស្រីអាចចូលរួមប្រាប់គាត់ដែរទៅពេលខ្លះគាត់ភ្លេចដែរចឹងណាស់ ចុះបងកើតនៅថ្ងៃខែឆ្នាំណា ដែរបងមានចងចាំទេ?

ខៈ ខ្ញុំមិនចងចាំទេលោកគ្រូអើយភ្លេចអស់ហើយនឹង

កៈ ចុះបងការនឹងបងមិនចងចាំដែរហោសបង?

ខៈ ខ្ញុំការនៅឆ្នាំណាទេខ្ញុំភ្លេចហើយលោកគ្រូអើយ

កៈ ចុះកូនរបស់បង ដែរបងគេនឹងអាយុប៉ុន្មានដែរបង?

ខៈ កូនរបស់ខ្ញុំដែរបងគេនឹងអាយុ19ឆ្នាំហើយនឹង ហេ កូនបងឈ្មោះសេងហ័ណនឹងអាយុ21ឆ្នាំហើយ

កៈ ប៉ុន្តែដូចជាបងការហើយភ្លាមបងមានកូនភ្លាមរឺយ៉ាងណាដែរបង?

ខៈ ខ្ញុំការហើយចោលពោះបានមួយឆ្នាំដែរ

កៈ ចឹងមានន័យថាបងការអស់ប្រហែលជា23ឆ្នាំហើយណាបង?

ខ៖ នឹងហើយខ្ញុំការអស់ប្រហែលជា23ឆ្នាំហើយបានមាននឹង

ក៖ ចុះឆ្នាំខ្មែរលក្ខណៈឆ្នាំជូត ឆ្លូវ ខាល ថោះហាសបងឆ្នាំអីគេដែរបង?

ខ៖ ឆ្នាំខ្មែរហោសបងគេនឹង?

ក៖ អត់ទេនិយាយពីឆ្នាំបងនឹង?

ខ៖ ខ្ញុំឆ្នាំម៉ែ្សាញ់នឹង

ក៖ ចុះបងកើតនៅណាដែរបង?

ខ៖ ខ្ញុំកើតនៅច្រកស្តៅហោស?

ក៖ នៅភូមិអី ឃុំអី ស្រុកអី ខេត្តអីគេដែរបង?

ខ៖ នឹងនៅភូមិច្រកស្តៅ ឃុំរអាងនឹងដែរ ស្រុកកំពង់សៀម ខេត្តកំពង់ចាមនឹងដែរនឹង

ក៖ អ៊ូ!ចឹងហោសបង?

ខ៖ គ្រាន់តែថាភូមិវាផ្សេងគ្នាចឹងណាស់

ក៖ ចុះបងមានបងប្អូនចំនួនប៉ុន្មាននាក់ដែរបង?

ខ៖ បងប្អូនបង្កើតរបស់ខ្ញុំមានច្រើនណាស់លោកគ្រូអើយ11នាក់នឹង

ក៖ អ៊ូ!មានច្រើនណាស់ ចុះមានស្រីប៉ុន្មាន ហើយមានប្រុសប៉ុន្មាននាក់ដែរបង?

ខ៖ មានស្រី2នាក់ ហើយនឹងប្រុស9នាក់នឹង

ក៖ អ៊ូ!ចុះបងជាកូនទីប៉ុន្មានដែរទៅបង?

ខ៖ ខ្ញុំជាកូនបងគេបង្អស់នឹង

ក៖ ចុះប្អូនៗរបស់បងនឹងបងអាចប្រាប់ឈ្មោះពួកគាត់ដែរបានទេបង?

ខ៖ បានតើ!

ក៖ គាត់មានឈ្មោះអីគេខ្លះដែរទៅបង?

ខ៖ ឈ្មោះស្រឿន គីមសេង, ស្រឿន គីមសាន្ត, ស្រឿន សៀងលី, ស្រឿន សុភ័ក្រ, ស្រឿន ធារី, ស្រឿន ធារ៉ា, ស្រឿន ម៉ារី, ស្រឿន ប្រុស, ស្រឿន ភារិណា,

ក៖ អស់ហើយណាបង?

ខ៖ អស់ហើយនឹង

ក៖ ចុះពៅគេមានឈ្មោះអីគេដែរបង?

ខ៖ ឈ្មោះស្រឿន ម៉ារី

ក៖ ចុះបងគិតមានកាលពីនៅក្មេងនឹង តើបងធ្លាប់មានសាច់រឿងអីជាមួយគ្នាទេ ដូចជាអនុស្សាវរីយ៍អីទេ ជាមួយបងប្អូនរបស់បងដែរចឹងណាស់?

ខ៖ ខ្ញុំគ្មានទេលោកគ្រូអើយប្រឹងតែរកលុយនឹងរកស៊ីរៀងខ្លួននឹង

ក៖
ប៉ុន្តែកាលពីនៅក្មេងៗតើងបងមានធ្លាប់លេងលក្ខណះថាលេងឡឹកបាយឡអីជាមួយគ្នាដែរចឹង ហាសបងមានទេ?

ខ៖ លេងដែរតើលោកគ្រូលេងបាយឡឹកបាយឡនឹង

ក៖ មានធ្វើអីគេខ្លះដែរទៅបងកាលពីនៅក្មេងៗនឹង?

ខ៖ លេងបាយឡឹកបាយឡ លេងនឹងដូចជាចង់ភ្លេចអស់ហើយលោកគ្រូអើយ

ក៖ ចុះបងចូលចិត្តលេងអីគេដែរកាលពីនៅក្មេងជាមួយបងប្អូនរបស់បងដែរ?

ខ៖ មានលេងដែរនឹង

ក៖ លក្ខណះលេងចុយ លេងឡឹកបាយឡ លេងគប់ឈូស អីចឹងហាសបង?

ខ៖ លេងលោតអន្ទាក់លេងអីនឹងណាស់

ក៖ លេងបិទពួនអីចឹងទៅណាបង?

ខ៖ នឹងហើយចេះតែលេងហើយនឹង

ក៖ ចុះប្អូនរបស់បងនឹងសព្វថ្ងៃពួកគាត់នៅណាខ្លះដែរទៅបង?

ខ៖ ខ្លះគេទៅនៅចំការលើ ខ្លះគេនៅនឹង ខ្លះគេទៅនៅថ្មគោល នៅបែកគ្នាអស់ហើយលោកគ្រូអើយ

ក៖ ចុះពួកគាត់ធ្វើអីគេខ្លះទៅបង?

ខ៖ ធ្វើការស៊ីឈ្នួលគេនឹងលោកគ្រូអើយ

ក៖ នៅចំការលើនឹងគាត់ធ្វើអីគេដែរបង?

ខ៖ នៅចំការលើនឹងគ្នាចំរះទៅអីទៅនឹងល្មមនឹងបានលុយមកនឹង

ក៖ ចឹងដូចជាប្អូនរបស់បងនឹងនៅចំការលើនឹងគាត់ស៊ីឈ្នួលចំរះអីគេទៅ?

ខ៖ ស៊ីឈ្នួលចំរះស្មៅអីអោយគេ

ក៖ ចុះប្អូនៗរបស់បងផ្សេងៗទៀតនឹងគាត់នៅណាដែរទៅបង?

ខ៖ នៅនេះអុកអាចម៍រណាអីចឹងលោកគ្រូអើយការងារតិចតួចនឹង

ក៖ អ៎ូ!គាត់ធ្វើការងារអីគេដែរទៅបង ប៉ុន្តែពួកគាត់មានគ្រួសារហើយអស់បង?

ខ៖ មានដែរហើយនឹង

ក៖ ប្អូនពៅរបស់បងក៏មានដែរហោសបង?

ខ៖ នៅទេប្អូនពៅនោះ

ក៖ ចុះឪពុករបស់បងមានឈ្មោះអីគេដែរទៅបង?

ខ៖ ប៉ារបស់ខ្ញុំបង្កើតនឹងឈ្មោះស្រឿន នឹងណាស់

ក៖ ចុះគាត់អាយុប៉ុន្មានដែរបងមានដឹងទេបង?

ខ៖ គាត់ឆ្នាំរកាគាត់អាយុហុកជាងហើយនឹង

ក៖ ប៉ុន្តែគាត់កើតនៅថ្ងៃខែឆ្នាំណាបងមានដឹងទេ?

ខ៖ អត់ដឹងទេលោកគ្រូអើយ ដឹងតែគាត់ឆ្នាំរកាទេ

ក៖ ប៉ុន្តែគាត់អាយុហុកប៉ុន្មានបងមានដឹងទេ?

ខ៖ គាត់អាយុ63ឆ្នាំហើយនឹងគាត់ចាស់ហើយនឹង

ក៖ ចឹងគាត់កើតនៅឆ្នាំ1955បង?

ខ៖ នឹងហោស

ក៖ បាទចុះគាត់កើតនៅណាដែរបងមានដឹងទេ?

ខ៖ គាត់កើតនៅព្រែកគុយហោស

ក៖ ព្រែកគុយនឹងនៅណាដែរបង?

ខ៖ ព្រែកគុយនឹងទៅចឹងទៅ

ក៖ នៅខាងល្វលហោសបង?

ខ៖ ទៅខាងល្វលនឹង ទៅខាងល្អៀកអីចឹងទៅណាស់

ក៖ អូ៎!ខាងល្អៀក ច្រាននឹងហោសបង?

ខ៖ នឹងហើយឆ្លងទៅទៀតនឹងហោស

ក៖ ម្ដាយរបស់បងគាត់មានឈ្មោះអីគេដែរទៅបង?

ខ៖ ម្ដាយរបស់ខ្ញុំនឹងឈ្មោះហោត

ក៖ ចុះគាត់ឆ្នាំអីគេដែរបងឆ្នាំខ្មែរហោស?

ខ៖ គាត់ឆ្នាំខ្មែរនឹងគាត់ឆ្នាំច

ក៖ ឆ្នាំចហោសបង?

ខ៖ នឹងហើយប៉ារបស់ខ្ញុំនឹងឆ្នាំរកា ហើយម៉ែរបស់ខ្ញុំឆ្នាំច

ក៖ ប៉ុន្តែយាយហើយនឹងតានឹងគាត់បងប្អូនគ្នាប៉ុន្មានឆ្នាំដែរបង?

ខ៖ គាត់បងមួយឆ្នាំ នឹងប្អូនមួយឆ្នាំនឹង

ក៖ ចឹងមានន័យថាយាយកើតនៅឆ្នាំ1956យាយហោស?

ខ៖ ចា៎!នឹងហើយ

កៈ  ប៉ុន្តែយាយគាត់កើតនៅណាដែរបង?

ខៈ  គាត់នឹងមិនដឹងទេលោកគ្រូអើយ

កៈ  ចុះឪពុករបស់បងនឹងគាត់ធ្វើអីគេដែរសំរាប់ចិញ្ចឹមជីវិតដែរបង?

ខៈ  គាត់ឡើងត្នោត ធ្វើស្រែចំការ គាត់នៅលើងត្នោតរាល់ថ្ងៃនឹងណាស់

កៈ  និយាយចឹងគាត់នៅរស់ទេហោសបង?

ខៈ  គាត់នៅរស់ទេគាត់នៅឡើងត្នោតរាល់ថ្ងៃនឹងណាស់

កៈ  អូ៎!គាត់ចាស់ហើយគាត់នៅតែឡើងត្នោតទៀត?

ខៈ  គាត់ចាស់ហើយចុះបើមិនខំប្រឹងគាត់បានអី
ពឹងកូនយ៉ាងម៉េចបើកូនសុទ្ធតែក្រៗដែរនឹង

កៈ  ចុះគាត់ជាមនុស្សយ៉ាងម៉េចដែរបង ស្លូតរឺមួយក៏កាចដែរបង?

ខៈ  គាត់កាចដែរនឹងណាស់

កៈ  ចុះម្តាយរបស់បងវិញ?

ខៈ  គាត់ស្លូតដែរនឹង

កៈ  ចុះគាត់ធ្វើអីគេសំរាប់ចិញ្ចឹមជីវិតដែរទៅ?

ខៈ  គាត់នៅជួយមើលការខុសត្រូវក្នុងផ្ទះ

កៈ  អូ៎!ប៉ុន្តែគាត់ស្លូតទេបង?

ខៈ  ចាំ!គាត់ស្លូតដែរទេនឹង

កៈ
ចុះបងមានចងចាំទេថាកាលពីបងនៅជាមួយក្រុមគ្រួសាររបស់បងនឹងតើបងធ្លាប់មានអនុស្សាវរីយ៍ គេខ្លះដែរមួយឪពុកម្តាយរបស់បងខ្លះដែរទេ?

ខៈ  ខ្ញុំនៅជាមួយម្តាយរបស់ខ្ញុំហោស?

កៈ  ទាំងឪពុកនឹងទាំងម្តាយធ្លាប់មានអនុស្សាវរីយ៍អីជាមួយពួកគាត់ដែរ?

ខ៖ ធ្វើស្រែធ្វើចំការ ធ្វើស្កូឡើងត្នោតអីគេដែរដូចតែគ្នានឹង គាត់ឡើងត្នោតតាំងពីខ្ញុំនៅតូចៗមកនឹង គាត់ឈប់ឡើងមួយរយះហើយតើ ដល់ពេលនឹកឃើញថាគាត់មិនដឹងរកស្អី ការងារសំណាង់ក៏គេលែង ត្រូវការគាត់ចឹងគាត់ក៏ទៅឡើងត្នោតវិញទៅណាស់

ក៖ ចុះជាមួយម្តាយរបស់បងតើបងធ្លាប់មានប្រវត្តិអីជាមួយគាត់ខ្លះដែរទេ?

ខ៖ ខ្ញុំដាំអំពៅ ទូលត្រីអីលក់នឹង

ក៖ ជាមួយម្តាយរបស់បងហោស?

ខ៖ ចា៎!នឹងហើយ

ក៖ ដូចលក្ខណះថាធ្វើបាយធ្វើម្ហូបអីជាមួយពួកគាត់ដែរចឹងទៅបង?

ខ៖ ចា៎!នឹងហើយ

ក៖ ចុះឪពុករបស់បងគាត់មានធ្លាប់ប្រាប់ពីប្រវត្តិកាលពីគាត់នៅក្មេងទៅបងដែរទេ?

ខ៖ អត់ដែរទេ

ក៖ ចឹងអត់ទេណបង ចុះម្តាយវិញបង?

ខ៖ គាត់មិនដែរប្រាប់ដែរនឹង

ក៖ អត់ដែរហោសបង ចុះយាយតាខាងឪពុកនឹងបងមានស្គាល់ឈ្មោះគាត់ដែរទេ?

ខ៖ ស្គាល់ដែរតើលោកគ្រូ

ក៖ ចុះគាត់មានឈ្មោះអីគេខ្លះដែរបង?

ខ៖ គាត់មានឈ្មោះឈន អេង ហើយ ម្តាយខាងឪពុកឈ្មោះស្រ៊ីន ហ៊ាង

ក៖ ចុះកាត់អាយុប៉ុន្មានដែរបងមានដឹងទេ?

ខ៖ គាត់ស្លាប់បាត់ហើយនឹង ទើបតែស្លាប់ប៉ុន្មានថ្ងៃនឹង

ក៖ ចឹងមានន័យថាគាត់ទើបតែស្លាប់ថ្មីៗនឹងទេ?

ខ៖ នឹងហើយទើបតែស្លាប់តើនឹង

កៈ  ប៉ុន្តែគាត់ស្លាប់នឹងអាយុប៉ុន្មានដែរបងមានដឹងទេ?

ខៈ  គាត់ស្លាប់នឹងអាយុ83ឆ្នាំ

កៈ  ចឹងគាត់ស្លាប់អាយុ83ឆ្នាំណាបង នឹងតារឺមួយក៏យាយដែរបង?

ខៈ  នឹងតា

កៈ  ចឹងគាត់ស្លាប់អាយុ83ឆ្នាំចឹងគាត់កើតនៅណាដែរបងមានដឹងទេ ទាំងតាទាំងយាយហាសបង?

ខៈ  អត់ដឹងទេលោកគ្រូអើយ

កៈ  ចុះយាយអាយុប៉ុន្មានដែរបងមានដឹងទេ?

ខៈ  មានអាយុ80ឆ្នាំ

កៈ  ចឹងមានន័យថាតាគាត់កើតនៅឆ្នាំ1935 ហើយយាយវិញគាត់កើតនៅឆ្នាំ1938បង

ខៈ  អ៎ូ!ចឹងហោសលោកគ្រូ

កៈ  ចុះយាយតាខាងឪពុកវិញបង?

ខៈ  មិញយាយតាខាងឪពុកហើយនឹង

កៈ ចុះយាយតាខាងម្តាយវិញបង?

ខៈ  យាយតាខាងម្តាយក៏គាត់អាយុ80ឆ្នាំដែរ

កៈ  ចុះតាវិញបង?

ខៈ

តាគាត់ស្លាប់បាត់ទៅប្រហែលជាអាយុគាត់នឹង70ឆ្នាំពីព្រោះខ្ញុំនៅបីទទឹងទេណាស់កាលបីគាត់ស្លាប់ នឹងហោសខ្ញុំលឺម្តាយរបស់ខ្ញុំនឹងគាត់ប្រាប់ខ្ញុំ

កៈ  បាទបង ចុះយាយតាខាងម្តាយនឹងគាត់មានឈ្មោះអីគេខ្លះដែរបង?

ខៈ  មានឈ្មោះឈន អេង

កៈ  នឹងខាងណាបង?

ខ៖ ឈ្មោះឈន អេង នឹងខាងយាយហាស ខាងម្ដាយរបស់គាត់តទៅទៀតហោស?

ក៖ បាទបងស្គាល់ទេ?

ខ៖ អត់ស្គាល់ទេនឹង

ក៖ អត់ទេចង់និយាយថាយាយតាខាងម្ដាយនឹងគាត់មានឈ្មោះអីគេដែរ?

ខ៖ នឹងហើយយាយតាខងម្ដាយនឹងឈ្មោះ ឈន អេង នឹងខាងម៉ែរបស់ខ្ញុំនឹង

ក៖ នឹងតា រឺក៏យាយឈ្មោះឈន អេងនឹង?

ខ៖ យាយឈ្មោះអេង តាឈ្មោះឈន

ក៖ អូ!ឈ្មោះឈន អេងនឹងទាំងតាទាំងយាយហោសបង?

ខ៖ នឹងហើយ

ក៖ ប៉ុន្តែពួកគាត់កើតនៅណាដែរបងមានដឹងទេ?

ខ៖ ពួកគាត់នៅច្រកស្ដៅហោស ប៉ុន្តែពួកគាត់ស្លាប់ងស់ហើយនឹង

ក៖ ប៉ុន្តែបងមករស់នៅនឹងយូរនៅបង?

ខ៖ ខ្ញុំមករស់នៅតាំងពីខ្ញុំនៅតូចមកនឹងម៉ែរបស់ខ្ញុំដូចថាគេនៅជំនាន់ណុង គេថាអ្នកណាមកនៅនឹងគេ ចែកដីអោយមួយប្លង់ម្នាក់

ក៖ អូ!ចឹងហោសបង?

ខ៖ ដល់ពេលចឹងខំនាំគ្នាមកប៉ុន្តែគេអ្នកដែរមិនមកគេនៅតែបានដែរ

ក៖ អូ!ម៉េចចឹងបង?

ខ៖ មិនដឹងយ៉ាងម៉េចទេ ប្រធានភូមិកាលណុង ដូចថាគេចែកថ្មកំប៉ែតមកនរណាគេមកនៅវាលខ្សាច់ យើងនឹងគេចែកដីអោយនៅដែរ ប៉ុន្តែគេមិនមកនឹងក៏គេបានដែរ

ក៖ ចុះបង?

ខ៖ ចឹងបានថាលោកគ្រូមកសួរនាំចឹងខ្ញុំចង់ណាស់មែនតើ ចង់ដូចថាចែកដីនរណាបានបានទៅ នរណាគេមិនបានមិនបានទៅ

ក៖ អូ៎!អត់ស្មើភាពគ្នាហោសបង?

ខ៖ មិនស្មើភាពគ្នាទេនឹង

ក៖ អូ៎!បាទបងបាទ?

ខ៖ ចឹងបានខ្ញុំថាកូនរបស់ខ្ញុំនឹងស្តាយណាស់មានប្រុស2នាក់នឹងអានេះមួយ អាបងមួយវាមិនបានរៀន សូត្រអោយបានដល់ចប់នឹងគេ ខ្ញុំស្តាយកូនរបស់ខ្ញុំណាស់រាល់ថ្ងៃនឹង

ក៖ បាទបងចឹង?

ខ៖ ពីព្រោះអីជីវភាពរបស់ខ្ញុំនឹងវាក្រហើយកាលពីជំនាន់ណុងខ្ញុំវាឈឺហាស បើពេលណុងខ្ញុំមិនឈឺទេ នឹងខ្ញុំនឹងតស៊ូអោយកូនវារៀនបានចេះដឹងណាស់

ក៖ ចុះបងមានបងប្អូនជីដូនមួយ រឺមួយក៏កូនចៅណាដែររស់នៅក្រៅប្រទេសទេបង?

ខ៖ អត់មានទេលោកគ្រូអើយ

ក៖ នៅប្រទេសថៃ នឹងប្រទេសវៀតណាមអីក៏អត់មានដែរ?

ខ៖ អត់មានទេមានតែនៅនឹង ចឹងបានថាល្ងង់ពេកអត់បានទៅដល់ប្រទេសក្រៅទេលោកគ្រូអើយ

ក៖ បាទបង ចុះស្វាមីរបស់បងគាត់មានឈ្មោះអីគេដែរបង?

ខ៖ គាត់មានឈ្មោះអៀង ហាក់

ក៖ ចុះបងមានចងចាំថាបងបានរៀបអាពាហ៍ពិពាហ៍នៅថ្ងៃខែឆ្នាំណាដែរទេបង?

ខ៖ អត់មានចងចាំទេលោកគ្រូ

ក៖ ប៉ុន្តែដឹងតែកូនបងរបស់បងនឹងអាយុ21ឆ្នាំ?

ខ៖ នឹងហើយគេអាយុ21ឆ្នាំនឹង

កៈ ចឹងមានន័យថាការអស់23ឆ្នាំហើយណាបង?

ខៈ នឹងហើយ

កៈ ចុះបងគិតថាពេលដែរបងរៀបអាពាហ៍ពិពាហ៍នឹងតើងបងជាអ្នករៀចំដោយខ្លួនឯង រឺមួយក៏ឪពុកម្ដាយ របស់បងជាអ្នករៀបអោយដែរ?

ខៈ ឪពុកម្ដាយនឹង

កៈ មានជាថ្លៃទឹកដោះ លក្ខណះថាជាថ្លៃចំនូនទេបង?

ខៈ មានតើ!

កៈ ដូចជាបានប៉ុន្មានដែរបងអាចប្រាប់បានទេ?

ខៈ ជំនាន់ណុងបាន4ជីមាស

កៈ ប៉ុន្តែកាលណុងថោកដែរតើហីបង?

ខៈ មាសកាលណុងមួយជី10មុឺន

កៈ ចឹងលុយថ្លៃហោសបង?

ខៈ នឹងហើយលុយថ្លៃ

កៈ
អូ្ន!បាទចុះបងអាចប្រាប់ពីពេលដំបូងចង់និយាយពីប្រវត្តិស្នេហាដូចជាពេលដំបូងដែរបងបានជួបប្ដី របស់បងនៅពេលណាដូចជាគាត់ស្រលាញ់បងប៉ុន្មានខែ
ប៉ុន្មានឆ្នាំបានគាត់ចូលស្ដីដណ្ដឹងបងចឹងហាស?

ខៈ គ្មានចេះស្រលាញ់គ្នាទេកាលពីជំនាន់ណុង
លក្ខណះថាគេចង់ចូលស្ដីដណ្ដឹងនឹងចង់មួយឆ្នាំអីដែរ នឹងបានការ

កៈ ប៉ុន្តែយើងស្គាល់គ្នាយូរហើយមែនទេ?

ខៈ ស្គាល់បានមួយឆ្នាំហើយនឹង ស្គាល់នឹងដូចជាមិនសូវជាស្គាល់ផងនឹង

កៈ ចុះយើងធ្វើអីគេដែរបានជាស្គាល់គ្នានឹង?

ខ៖ គ្មានធ្វើអីទេមើលគោគាត់នៅនិយាយប្រាប់ខ្ញុំដែរខ្ញុំនៅចងចាំ

ក៖ អូ!នៅមើលគោជាមួយគ្នាហោសបង?

ខ៖ គាត់នៅមើលគោជាមួយខ្ញុំនឹង ខ្ញុំគិតថាគាត់នេះមកពីណាខ្ញុំមានយកចិត្តទុកដាក់អីខ្ញុំ

ក៖ អូ!បាទបង ចុះកាលពីបងការនឹងនៅអាយុប៉ុន្មានដែរបង?

ខ៖ កាលពីខ្ញុំការនឹងនៅអាយុ18ឆ្នាំនឹង

ក៖ អូ!នៅអាយុ18ឆ្នាំ ចុះសំរាប់បងចេះអាន
រឺមួយក័ចេះសរសេរអក្សរខ្មែរបានល្អប៉ុណ្ណាដែរបង?

ខ៖ ខ្ញុំចេះបានតិចៗទេលោកគ្រូអើយ

ក៖ បងរៀនបានថ្នាក់ទីប៉ុន្មានដែរបង?

ខ៖ ខ្ញុំរៀនបានថ្នាក់ទី2នឹង

ក៖ ចុះកាលណុងបងរៀននៅសាលាបឋមសិក្សានៅណាដែរបង?

ខ៖ ខ្ញុំរៀននៅសាលាបឋមសិក្សានៅសាលាថ្មគោលយើងនេះ

ក៖ ចឹងបងរៀននៅថ្មគោលហោស ចុះបងធ្លាប់មានមិត្តភក្តិដែរធំធាត់មកជាមួយគ្នាទេបង?

ខ៖ មានតើលោកគ្រូ

ក៖ មានឈ្មោះអីគេខ្លះដែរបង បងអាចប្រាប់ឈ្មោះដែរបងនៅរងចាំបានទេ?

ខ៖ មិត្តភក្តិរបស់ខ្ញុំនឹងនៅថ្មគោលហោស

ក៖ ប៉ុន្តែឈ្មោះអីគេដែរទៅ?

ខ៖ មានឈ្មោះមីអ៊ាមួយ មីពេជ្រមួយនៅណុង

ក៖ អូ!បាទបង ចុះបងមានចងចាំអនុស្សាវរីយ៍អីជាមួយពួកគាត់ដែរទេបង?

ខ៖ ថ្លាប់លេងដែរ

ក៖ ធ្លាប់លេងអីគេជាមួយគ្នាដែរទៅ?

ខ៖ ធ្លាប់លក្ខណៈថាពេលនៅសាលាចឹងនាំគ្នាលោតអន្ទាក់ លេងលោតកំពស់

ក៖ ចុះមានថ្លាប់ដើរលេងអីជាមួយគ្នាដែរទេបង?

ខ៖ អត់ទេ

ក៖ ចឹងអត់ដែរទេហោសបង?

ខ៖ រហូតទាល់តែនៅបែកគ្នារៀងខ្លួនមក

ក៖ ចុះបងមានចេះភាសាអីក្រៅពីភាសាខ្មែរដែរទេបង?

ខ៖ ខ្ញុំអត់ចេះទេលោកគ្រូ

ក៖ វៀតណាម ថៃ បារាំងអិក៏អត់ចេះដែរណា?

ខ៖ អត់ចេះទាល់តែសោះនឹង

ក៖ ចុះបងធ្លាប់បានធ្វើការនៅស្រែចំការទេបង?

ខ៖ ធ្លាប់ដែរនឹង

ក៖ ប៉ុន្តែឥឡូវនឹងក៏នៅតែធ្វើដែរហៅបង?

ខ៖ ឥឡូវនឹងឈប់ហើយលោកគ្រូអើយគ្មានដីស្នូង ស្រែទេ

ក៖ ចុះបងមានធ្លាប់បើកអាជីវកម្មលក់ដូរអីដែរទេបង?

ខ៖ អត់ទេលោកគ្រូអើយ

ក៖ ចឹងអត់មានទេ?

ខ៖ នឹងហើយខ្ញុំដើរស៊ីឈ្នួលគេចឹងទៅ ដើរទិញឈ្មូកគេអីតិចតួចអីចឹងទៅណាស់

ក៖ ចុះលក្ខណៈសត្វវិញលក្ខណៈថាចិញ្ចឹមគោ ក្របី មាន់ ទា ជ្រូកវិញបង?

ខ៖ ខ្ញុំចិញ្ចឹមគោ

ក៖ ចឹងចិញ្ចឹមជាលក្ខណៈកសិដ្ឋានវីមួយក៏ចិញ្ចឹមជាលក្ខណៈគ្រួសារដែរបង?

ខ៖ ចិញ្ចឹមជាលក្ខណៈគ្រួសារ

កៈ ចិញ្ចឹមតិចដែរហោសបង?

ខៈ ចិញ្ចឹមតិចដែរនឹងចិញ្ចឹម3-4គោនឹង

កៈ ចុះបងគិតថាតាំងពីក្មេងហា
រហូតមកដល់ឥឡូវនឹងបងគិតថាបងធ្លាប់ធ្វើការងារអីគេខ្លះដែរបង?

ខៈ តាំងពីក្មេងមកនឹងខ្ញុំគ្មានធ្វើការអីបើមិនដែរទៅធ្វើរោងចក្រផងនឹង
ធ្វើការនៅស្រែចំការដើរគេជួល អោយទៅដាំអំពៅអីចឹងទៅ

កៈ
ចុះបងគិតថាជីវិតរបស់បងមានការផ្លាស់ប្តូរអីគេខ្លះដែរបងតាំងពីក្មេងរហូតមកដល់ពេល
នេះ?

ខៈ ខ្ញុំគ្មានអីផ្លាស់ប្តូរអីទេលោកគ្រូអើយ នៅតែដដែលនឹង

កៈ ប៉ុន្តែគិតថាពីក្មេងមានការផ្លាស់ប្តូរអីគេដែរដល់ឥឡូវនឹងណាស់?

ខៈ អត់មានការផ្លាស់ប្តូទេមុខរបរម៉េចនៅតែចឹង

កៈ ចុះបងគិតថាបងចូលចិត្តពិសារម្ហូបអីគេដែរបង?

ខៈ ខ្ញុំអីក៏បានដែរនឹង

កៈ ចុះលក្ខណៈថាដូចជាសំលស្ងោរ ម្ជូរ ឆា ការី ចៀនអីចឹងហាសបង?

ខៈ ចំរុះម្ហូប

កៈ ចឹងមានន័យថាបងចូលចិត្តចំរុះម្ហូប បងចូលចិត្តទាំងអស់នឹង?

ខៈ ខ្ញុំចូលចិត្តទាំងអស់នឹង

កៈ ចុះកាលពីនៅក្មេងល្បែងប្រជាប្រិយ៍អីដែរបងគិតថាបងចូលចិត្តលេងដែរបង?

ខៈ អត់ដែរសោះហើយនឹង

កៈ ដូចជាលក្ខណៈថាចោលឈូង បោះអង្គុញ ទាញព្រាតអីចឹងហាស?

ខ៖ ដែរតើ លោកគ្រូ
ទៅដូចថាចូលឆ្នាំអីចឹងទៅគេទៅលេងអីចឹងតៅនឹងគេហើយនឹងបោះឈូង
ទាញព្រាតអីនឹង

ក៖ បាទបងចុះបងចេះច្រៀងទេបង?

ខ៖ ខ្ញុំមិនចេះទេ ប៉ុន្តែខ្ញុំចេះច្រៀងខាងក្រៅ ច្រៀងលេងចឹងទៅ

ក៖ លក្ខណះបុរាណរឺក៏ស្រម៉ៃ?

ខ៖ ច្រៀងបទបុរាណ

ក៖ ប៉ុន្តែបទអីដែរបងចងចាំហាស មានចងចាំចំណាងជើងបទចំរៀងទេបង?

ខ៖ ចំណង់ជើងឆ្កាច់ឆ្កូវ

ក៖ ចំណាងជើងឆ្កាច់ឆ្កូវ?

ខ៖ ច្រៀងលេងធម្មតាឆ្កាច់ឆ្កូវនឹង

ក៖ ចុះបងអាចដាក់មួយឃ្លបានទេបង?

ខ៖ ខ្ញុំអាចដាក់បានតើ!

ក៖ អ៊ូ!បានហោសបង?

ខ៖ បានមែនតើ!

ក៖ ចឹងបងដាក់មួយឃ្លាទៅបង?

ខ៖ ចាំ!ខ្ញុំច្រៀងមិនដឹងច្រៀងថាម៉េចទេនេះដីស្រែវាលស្រូវទៅនោះ

ក៖ បាទដីស្រែវាលស្រូវ?

ខ៖ ប៉ុន្តែខ្ញុំចេះមិនចប់ទេណាស់

ក៖ បងចេះប៉ុណ្ណាដាក់ប៉ុនណុងទៅបង?

ខ៖ ចឹងហោស ដីស្រែវាលស្រូវនៅចាំទាំងអស់ មានតែប៉ុណ្ណឹងទេលោកគ្រូអើយ

កៈ បាទខ្ញុំនិយាយលេងទេបងបងចេះបានប៉ុណ្ណឹងក៏បានដែរបង?

ខៈ ចាំ!មានតែប៉ុណ្ណឹងដែរចេះ

កៈ ចុះបងចូលចិត្តស្តាប់បទចំរៀងទេបង?

ខៈ ខ្ញុំចូលចិត្តស្តាប់ណាស់លោកគ្រូ

កៈ លក្ខណះបទបុរាណរឺមួយបទសម័យដែរបង?

ខៈ បទបុរាណ

កៈ ចុះលក្ខណះមើលល្ខោនយីកេអីបងចូលចិត្តមើលទេ?

ខៈ ចូលចិត្តតើលោកគ្រូ

កៈ ចុះបងអាចប្រាប់បានទេថាបងចូលចិត្តមើលនៅពេលណាអីបានទេលោកគ្រូ?

ខៈ ខ្ញុំអោយតែរួចរាល់ការងារអោយតែអោយគោស៊ីរួចនឹង ខ្ញុំចុលចិត្តមើលម៉ោង11

កៈ ប៉ុន្តែពេលណុងនៅពេលណាដែរបង នៅវ័យប៉ុណ្ណាដែរបង?

ខៈ ឥឡូវនឹង

កៈ ឥឡូវនឹងក៏ចូលចិត្តដែរ?

ខៈ ឥឡូវនឹងក៏ចូលចិត្តដែរ ពេលល្ងាចនឹងនាំកូនចៅហើយនឹងនាំទៅលើផ្ទះហើយនឹង

កៈ ចុះបងមាននរណារឺមួយក៏ក្រុមគ្រួសារចេះលេងឧករណ៌ភ្លេងដែរទេបង?

ខៈ អត់ទេលោកគ្រូ

កៈ អត់ទេហោសបង ភ្លេងពិនពាត ភ្លេងខ្មែរលក្ខណះថាអកកណ្តុងអីក៏អត់ដែរ?

ខៈ អត់ទេលោកគ្រូ នេះមីមួយនេះនៅក្មេងគេហៅទៅដែរតើនឹង

កៈ ហៅទៅធ្វើអីគេវិញបង?

ខៈ ហៅទៅច្រៀងអកកណ្តុងដែរតើនឹង តែមិនបានទៅ

កៈ
ចុះផ្ទះរបស់បងមានលក្ខណះបែបណាដែរបងតាំងពីក្មេងរហូតមកដល់ពេលនេះហាស?

ខៈ ខ្ញុំក្រណាស់លោកគ្រូនេះផ្ទះចាស់ទេនេះ

កៈ ផ្ទះនឹងហោសបង?

ខៈ ផ្ទះចាស់ទេនឹងហោស ផ្ទះនឹងខ្សែធំតែមួយប្រលោះប៉ុណ្ណឹងទេ

កៈ នឹងកាលនៅពីក្មេងមែនមីង?

ខៈ កាលនៅក្មេងកាលនៅពីតូចៗ

កៈ ប៉ុន្តែដល់ពេលធំទៅ?

ខៈ ដល់ពេលដែរធំទៅកូនជួយរកម្នាក់បន្តិចៗនឹង

កៈ បានបានធ្វើផ្ទះប៉ុណ្ណឹងទៅ?

ខៈ បានបានប៉ុណ្ណឹងណាស់

កៈ ប៉ុន្តែផ្ទះនឹងសាងសងដោយខ្លួនឯងរឺមួយក៏ជួលគេមកធ្វើដែរ?

ខៈ ជួលគេមកធ្វើ

កៈ យើងអោយលុយគេទៅអោយគេធ្វើអោយ?

ខៈ គ្រាន់តែធ្វើនឹងអស់500$ជាងហើយនេះ

កៈ ប៉ុន្តែប្តីរបស់បងនឹងចេះធ្វើផ្ទះទេ?

ខៈ ប្តីរបស់ខ្ញុំនឹងជាជាងសំណង់ផ្ទះតិចតួចអីនឹងគាត់ចេះ

កៈ ចុះគាត់ចេះមកពីនរណាគេដែរបានបង្រៀនគាត់ដែរ?

ខៈ គាត់ចេះតាមប៉ារបស់ខ្ញុំបង្កើតនឹង

កៈ ចុះបងមានជំនាញអីដែរបងគិតថាបងចេះស្ទាត់ជំនាញដែរទេបង?

ខៈ ខ្ញុំគ្មានស្ទាត់ជំនាញរឿងស្អីទេនឹង

កៈ លក្ខណៈជំនាញអីមួយដែរបងគិតថាបងចេះស្ទាត់ចឹងហាស
លក្ខណៈធ្វើស្រែរឺក៏ធ្វើអីមួយអោយ ប្រាកដចឹងណាស់ហាស?

ខៈ ធ្វើស្រែនឹងខ្ញុំស្ទាត់ជំនាញហើយធ្វើស្រែនឹង

កៈ ខាងលក្ខណៈដកស្ទូងហីបង?

ខៈ នឹងហើយដកស្ទូង ដាំបន្លែ

កៈ ចុះឪពុកម្ដាយរបស់បងនឹងគាត់ធ្លាប់បង្រៀនពីជំនាញអីទៅបងទេ
ដូចលក្ខណៈថាវេញវល្លិ៍ កូរស្កត្នោត រឺមួយក៏ធ្វើផ្ដៅ រឺធ្វើជាកន្ទេលអញ្ចូតអីចឹងហាស?

ខៈ គាត់ប្រើអោយខ្ញុំទៅលក់ដូរ

កៈ ចុះបងអាចប្រាប់ពីពេលដែរបងលំបាកនៅក្នុងជីវិតរបស់បងបានទេ
តាំងពីក្មេងរហូតមកដល់ពេល នេះចឹងហាស?

ខៈ លំបាកជួយម៉ែឪ ខ្ញុំជួយលើកអូសគាត់ជួយលើស្ករត្នោតអីចឹងទំរាំបានធមប៉ុណ្ណឹង
នេះលោកគ្រូខ្ញុំចេះ តែថាទេខ្ញុំសំលាក់មុខនឹងដោយសារតែជួយម៉ែឪនឹងណាស់
ដល់ពេលលើកស្ករទៅវាដួលជំពុបជើងដួល នឹងណាស់

កៈ ប៉ុន្តែបងចេះកូស្ករអត់?

ខៈ ខ្ញុំចេះតើ!

កៈ ប៉ុន្តែនៅពេលដែរពលពតបងមិនទាន់ទេហោសបង?

ខៈ ខ្ញុំមិនទាន់ទេ

កៈ ដូចជាពលពតហើយខ្មែរក្រហមមែនបង?

ខៈ នឹងហើយខ្មែរក្រហម

កៈ ចុះខ្មែរក្រហមនឹងបងធ្វើអីគេដែរបង?

ខៈ
កាលខ្ញុំកាលពេលគាត់ដឹងនឹងគាតដំណើរប្រាប់ខ្ញុំហាសគេថាគេអោយគាត់ទៅប្រជុំនៅរោ
ងបាយគេ ហាសចឹងគេប្រជុំនៅរោងបាយហើយយកអោយគាត់ហូប

ចឹងពេលអ្នកនៅជាមួយគាត់ពេលដែរគេបាន ឃើញរបបគាត់បានច្រើន
មានគេច្រណែនមានគេចង់យកមិត្តនឹងទៅបាញ់ចោលអីចឹងហាស

កៈ មួយនឹងជំនាន់ពលពតហោសបង?

ខៈ ចាំ!នឹងហើយជំនាន់ពលពត គាត់រៀនបានច្រើនគាត់ចង់ឡើងទៅធ្វើពេទ្យ
ប៉ុន្តែគេមានថាចឹងទៅគេ បានទំលាក់មិនអោយគាត់រៀនទេ

កៈ ចុះបើអ្នករៀនសូត្រលឺគេថាយកទៅរៀនសូត្រហីមីង?

ខៈ អ្នកចេះដឹងគេអោយគាត់រៀន ប៉ុន្តែមានអ្នកនឹងគេមិនចង់អោយគាត់ចេះ

កៈ បាទបងបាទ?

ខៈ គេទំលាក់មិនអោយគាត់ធ្វើពេទ្យទេគាត់រៀនពូកែទេ
ប៉ុន្តែគេទំលាក់គាត់ចោលមិនអោយធ្វើពេទ្យទេ

កៈ ប៉ុន្តែគេអោយបងទៅណាដែរទៅ?

ខៈ នៅនឹងតើ!

កៈ ប៉ុន្តែគេជំលាស់នៅខេត្តនឹងតាហី?

ខៈ នៅក្នុងខេត្តនឹង

កៈ ចឹងអត់មានទៅណាឆ្ងាយទេហោសបង?

ខៈ អត់មានទេ

កៈ ប៉ុន្តែឪពុកម្តាយរបស់បងនឹងធ្វើតែចឹងទេ មិនធ្វើអីទៀតទេ?

ខៈ ចាំ!នឹងហើយ

កៈ ចុះបន្ទាប់ពីចប់ពលពតបងធ្វើអីទៀតទៅ?

ខៈ គាត់ដាច់ពលពតនឹងគាត់មកនៅនឹង

កៈ
ចុះនៅពេលជំនាន់ខ្មែរក្រហមនឹងគិតថាគ្រួសាររបស់បងមានការលំបាកអីគេដែរទៅបង?

ខ៖ ខ្មែរក្រហមម៉ែរបស់ខ្ញុំពេលដែរខ្ញុំនៅតូចៗហាសលោកគ្រូ
ពេលដែរខ្ញុំនៅតូចៗគេរើសខ្ញុំទៅស្វាយត្រាំ
ដូចថាម៉ែរបស់ខ្ញុំនឹងគាត់មានតែកូនតូចចឹងហាស

ក៖ បាទបងបាទ?

ខ៖
គាត់មិនអាចទៅរកស៊ីអីបានទេដល់ពេលគេចាប់គាត់នឹងទៅធ្វើកងទ័ព្វស្វាយត្រាំនឹងគាត់វេទនាក្នុង នឹងហើយគាត់វេទនារកបាយអោយកូនសឹងមិនបានហូបទេ

ក៖ ចឹងហោសបងយ៉ាប់ដែរ?

ខ៖ ហើយបើមានគ្រាប់កាំភ្លើងបាញ់នឹងគេបញ្ជូនទៅលិច ទៅកើតនឹងបញ្ជូនគាត់នឹង
ខ្ញុំថាបើអត់បាយវា មធ្យម
ដូចជាបើសិនជាគាត់ត្រូវក្រាប់ផ្លោងទៅកាត់ស្លាប់ចោលកូនទៅវាមិនយ៉ាប់

ក៖ បាទបងនឹង?

ខ៖ ចឹងបានខ្ញុំនឹកឃើញរឿងនឹងម្ដងដូចជាក្ដៅដែរនឹង
ដូចក្ដៅថាវាកើតនៅជំនាន់ខ្មែរក្រហមនឹង

ក៖ វាបានកើតមកលើខ្មែរអីចឹង?

ខ៖ នឹងហើយដល់ពេលដែរកើតមកលើខ្មែរចឹងខ្មែរមិនបាននៅភូមិទេ
អត់បាននៅចិញ្ចឹមកូនទេទៅលិច ទៅកើត

ក៖ ចឹងបានថាក្មេងសម័យឥឡូវនឹងមិនបានស្គាល់ហាស?

ខ៖ គេមិនបានស្គាល់ទេ

ក៖ ពួកគាត់ចេះតែសប្បាយចឹងមិនដឹងចឹងហាសបង?

ខ៖ ខ្ញុំចេះតែសប្បាយហើយនឹងឥឡូវ
ប៉ុន្តែបើខ្ញុំនឹកឃើញរឿងនឹងពីព្រោះគេយកប៉ារបស់ខ្ញុំកូនតូចៗ ហើយម៉ែកូនតូចបានអីស៊ី

កៈ
បាទបងចុះបងគិតថានៅពេលដែរបងមានក្រុមគ្រួសារតើបងគិតថាបងមានការលំបាកអីគេដែរបង នៅពេលដែរបងចាប់ផ្តើមមានគ្រួសារហាស?

ខៈ ពេលដែរខ្ញុំចាប់ផ្តើមមានគ្រួសារហាសបងពិបាករហូតនឹង
ពិបាកថាដូចជាយើងមិនដឹងថាប្រកបមុខ របរអីទៅចិញ្ចឹមកូន

កៈ ចឹងហោសបង?

ខៈ ចឹងខ្ញុំតាំងចិត្តថាប្តីរបស់ខ្ញុំនឹងធ្វើការងារសំណង់
ចឹងខ្ញុំតាំងចិត្តថាអោយតែមានកងមួយនឹងមាន កញ្ច្រែងមួយទៅខ្ញុំនឹងទិញបន្លែដូចជាឈូកនឹងបន្លែននោង ឃ្លោកនៅផ្សារដើម្បីយកលុយមកទិញម្ហូប នឹងបាយអោយកូនហូបចឹងទៅ

កៈ ចុះបងគិតថាបងឆ្លងកាត់ការលំបាកមួយនឹងដោយរបៀបណាដែរទៅបង?

ខៈ ខ្ញុំឆ្លងកាត់នឹងនឹកឃើញថាយូរនឹងយកលុយមកអោយយើងណាស់
បើចឹងយើងតាំងចិត្តខ្លួនឯង ថាធ្វើម៉េចអោយកូនបានស៊ីអោយគ្រប់គ្រាន់

កៈ បាទត្រូវហើយបង

ខៈ ចឹងខ្ញុំមិនសូវជាអ្នកចេះចូលផ្សារប៉ុន្មានទេលោកគ្រូ
ប៉ុន្តែខ្ញុំទៅលក់ទៅដូរបន្លែអីតិចតួចចឹងទៅណាស់

កៈ បាទបងបាទ?

ខៈ ខ្ញុំក៏តាំងចិត្តខ្លួនឯងប្តីនឹងមិនមានដើមទុនទិញមងទេ
ខ្ញុំក៏តាំងចិត្តប្តីថាប្តីអើយទៅធ្វើការទៅខ្ញុំនៅផ្ទះ
ខ្ញុំអាចមានកងមួយជាលមួយទៅទិញបន្លែទៅលក់នៅផ្សារបានលុយចឹង

កៈ បាទល្អតើបង?

ខៈ
ដើម្បីយកមកចិញ្ចឹមកូនហើយខ្ញុំប្តីទៅធ្វើការខ្ញុំមិនសូវខ្វល់ទេយើងចេះរកខ្លួនយើងហើយនឹង

កៈ បាទបង
ចុះពេលណាដែរបងគិតថាជាពេលដែរសប្បាយនៅក្នុងឆាកជិវិតរបស់បងដែរចឹងហាស លក្ខណៈថាបងការខ្លួនឯងរឺមួយក៏ការកូនចឹង

ខៈ
ពេលដែរការកូនខ្ញុំមានអារម្មណ៍សប្បាយក្នុងចិត្តថាយើងមានមុខមានមាត់ដែរបានកូនការ

កៈ បាទត្រូវបងបានកូនការ?

ខៈ រួចទៅបើកូននឹងប្ដីរបស់គេចេះមានមុខរបររកស៊ី

កៈ គេអាចចិញ្ចឹមកូនយើងស្រួលចឹងទៅ?

ខៈ អាចចិញ្ចឹមកូនយើងស្រួលចឹងទៅយើងនឹងស្រាលនៅក្នុងជីវិតចឹងទៅ

កៈ អូ៎!បាទបងបាទ?

ខៈ អត់សួរជាគិតទេថានឹងគេអាចមានមុខរបរមួយហើយនឹង

កៈ ទោះយ៉ាងម៉េចក៏គេអាចចិញ្ចឹមកូនយើងស្រួលដែរនបង?

ខៈ គេអាចចិញ្ចឹមកូនយើងរស់ស្រួលនឹង

កៈ កុំអោយមានបញ្ហាអីទៅមុខនឹង?

ខៈ នឹងហើយវាចឹង

កៈ
ចុះបងគិតថាតាំងពីក្មេងបងគិតថាបងធ្លាប់មានក្ដីស្រម៉ៃថាពេលដែរបងធំឡើងតើបងចង់ធ្វើអីទេបង ដូចថាបងចង់ធ្វើជាគ្រូបង្រៀន ធ្វើពេទ្យរឺមួយធ្វើអីមួយចឹងហាសបង?

ខៈ ចង់ដែរតើ!លោកគ្រូ

កៈ ចុះបងចង់ធ្វើអីគេដែរទៅ?

ខៈ ដូចថាធំឡើងចង់ធ្វើជាគ្រូបង្រៀនអីចឹងទៅ
ចង់ថាពេលដែរមានលុយអីចង់ទៅបើកទិញតូបគេលក់
ខោអាវនៅក្នុងផ្សារអីចឹងហាសលោកគ្រូ

កៈ ប៉ុន្តែបងមិនទាន់បានសំរេចទេ?

ខៈ ប៉ុន្តែវាមិនទាន់បានសំរេចទេពីព្រោះយើង វាមិនទាន់មានដើមទុននឹងគេ

កៈ បាទបង
ចុះបើសិនជាចង់អោយបងផ្តែផ្តាំទៅកូនចៅជំនាន់ក្រោយៗតើបងចង់ផ្តែផ្តាំអីទៅពួកគាត់ដែរបង?

ខៈ ខ្ញុំចង់ដែរតើ!លោកគ្រូ

កៈ បងចង់ផ្តែផ្តាំអីគេខ្លះដែរទៅបង?

ខៈ ខ្ញុំចង់ថាអោយកូនរៀនអោយបានចេះដឹង អោយកូនទៅកូរ៉េអីចឹងទៅ
នឹងទៅអាមេរិចនឹងគេទៅ

កៈ បាទបងបាទ?

ខៈ
អូ៎!លោកគ្រូសំភាសន៍ខ្ញុំនឹងដូចជាខ្ញុំភ្លេចមួយជីដូនខ្ញុំមួយនឹងនៅល្អាងហោសគាត់បានបែកពីជំនាន់ ពលពតនឹងហាសលោកគ្រូ

កៈ ចុះយ៉ាងម៉េចទៅបង?

ខៈ
ហើយគេមានកូនមួយដល់ពេលដែរបែកទៅបាត់ទៅដល់ពេលដែរជំនាន់ឥឡូវនឹងដឹងដំណឹងចឹងទៅ
ដឹងថាកូនគាត់នឹងនៅអាមេរិចហោសនឹងហើយគាត់បើកយន្តមកចឹងទៅគាត់មានលុយច្រើនហាស ហើយក្បាលពោះគាត់នឹងដុះឡើងស្អុយ

កៈ ចឹងហោសបង?

ខៈ ដល់ពេលនេះខ្ញុំនៅតូចៗនឹងមានក្មួយមានប្អូនហើយខ្ញុំទៅលេងហាសណាស់
ពេលដែរទៅលេងចឹង
ទៅនាំគ្នាអៀនមិនទាន់ដឹងអីទេអ្នកទៅពួននៅកៀនជញ្ជាំងចឹងទៅនៅជិតជញ្ជាំងនឹងស្រាប់តែមានដង្កូវចូលក្បាល

កៈ
ចឹងដូចជាបងចង់សួរខ្ញុំរឿងអីគេវិញបងដោយសារតែបងថាបងមានបងប្អូននៅអាមេរិចហាស?

ខៈ ខ្ញុំចង់ប្រាប់លោកគ្រូរឿងនឹងហាស

កៈ ប៉ុន្តែគាត់រស់នៅរដ្ឋណាបងមានដឹងទេ?

ខៈ គាត់នៅសហរដ្ឋអាមេរិចនឹងប៉ុន្តែមិនដឹងថាគាត់នៅណាទេនឹង

កៈ ដើយសារតែនៅអាមេរិចវាធំហើយវាមានច្រើនរដ្ឋហាស

ខៈ ប៉ុន្តែខ្ញុំមិនបានដឹងទេលោកគ្រូ?

កៈ ចឹងចាំខ្ញុំសំភាសន៍ជាមួយបងហើយចាំខ្ញុំសាកនិយាយជាមួយបងបន្តិចដែរបង
ចុះបងមានអីដែរចង់ ផ្តែផ្តាំទៅកូនចៅជំនាន់ក្រោយៗផ្សេងទៀតទេបង?

ខៈ
ខ្ញុំចង់ផ្តែផ្តាំទៅកូននឹងថាអោយកូនរៀនបានខ្ពស់ទៅហោងស៊បបុណ្យយើងមានហាសលោកគ្រូ បានទៅអាមេរិចទៅវារៀងធូរដែរ
អោយតែអ្នកទៅអាមេរិចនឹងមុខរបរគេនឹងមិនដឹងយ៉ាងម៉េចទេ ប៉ុន្តែវាល្អ

កៈ បាទបងបាទ?

ខៈ ប៉ុន្តែទៅណុងមិនមែនណុងមិនមែនអ្នកក្រទេសុទ្ធតែអ្នកមាននឹង

កៈ
ចុះបើសិនជាចង់អោយកូនចៅជៀសរៀងវិញតើបងចង់អោយកូបចៅជៀសរៀងអីគេដែរបង?

ខៈ អត់ចង់អោយជៀសរៀងទេចង់អោយតែទៅប្រទេសគេនឹង

កៈ ដូចថាលក្ខណះថាអំពើមួយដែរមិនសូវ ល្អអីចឹងហាស?

ខៈ ជៀសរៀងគ្រឿងញៀន ជៀសរៀងផឹកស៊ីនឹងវៃគ្នានឹងលោកគ្រូខ្ញុំខ្លាចណាស់

កៈ មានអីដែរបងចង់អោយពួកគាត់ចៀសរៀងផ្សេងទៀតទេបង?

ខ៖ ចង់តើ!

ក៖ ចង់អោយជៀសវៀងអោយពួកគាត់ធ្វើអីទៅបង?

ខ៖ រឿងថាតមាត់ម៉ែឪអីចឹងទៅ

ក៖ បាទត្រូវហើយបង

ខ៖ រឿងតមាត់ម៉ែឪនឹងខឹងណាស់មិនចង់អោយមានរឿងចឹងទេលោកគ្រូ

ក៖
ចុះបើកូនចៅវិញតើបងចង់អោយពួកគាត់ធ្វើអីគេដែរទៅដូចថាលក្ខណះថាអោយពយកគាត់ខំប្រឹង រៀនអីចឹងនឹងមានការងារល្អអីចឹងហាសបង?

ខ៖ នឹងហើយអោយមានការងារល្អអីចឹង
ពេលដែរមានការងារល្អគ្រួសាររបស់យើងក៏រុងរឿងដែរនឹង

ក៖ បាទបងចឹងអត់មានរឿងអីផ្សេងទៀតទេហោសបង?

ខ៖ អត់មានទេ

ក៖ ចឹងជាចុងក្រោយខ្ញុំអរគុណច្រើនបងដែរបានអោយខ្ញុំសំភាសន៍ពីប្រវត្តិរបស់បង

ខ៖ អ៊ូ!ខ្ញុំអរណាស់លោកគ្រូខ្ញុំមិនចេះខឹងដូចគេទេនឹង
ដើម្បីគេណែនាំចឹងដើម្បីគេអោយយើងភ្លឺភ្នែក

ក៖ បាទបងដោយសារតែពេលខ្លះកូនចៅមិនសូវដឹងទេណាបង?

ខ៖ នឹងហើយមិនសូវដឹងទេ ពិតថាជំនាន់មុនមែនប៉ុន្តែយើងមិនបានរៀនសូត្រ
យើងមិនសូវបានដើរច្រើន ក៏យើងអាចល្ងង់ដែរនឹង

ក៖ បាទបងបាទ?

ខ៖ ចឹងពេលដែរលោកគ្រូមកសំភាសន៍ចឹងខ្ញុំអរណាស់ ខ្ញុំចូលចិត្តណាស់

ក៖ បាទចឹងខ្ញុំអរគុណច្រើនបង៕៕៕